**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២៧១ ព.ណ. ស.ជ.ណ

ភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសុខាភិបាល**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងទេសចរណ៍**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ**
**លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**
**ឯកឧត្តមអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
**ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកគយនិងរដ្ឋាករកម្ពុជា**
**ឯកឧត្តម នាយកសាលាភូមិន្ទរដ្ឋបាល**

**<u>កម្មវត្ថុ</u>:** សំណើសុំអញ្ជើញសមាជិកក្រុមការងារនៃគណៈកម្មាធិការអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ចូលរួមសិក្ខាសាលាស្តីពី **"How To Prepare A Bankable Project Proposal"** នៅទីស្តីការក្រសួងពាណិជ្ជកម្ម។

**<u>ជូនភ្ជាប់</u>:** របៀបវារៈនៃសិក្ខាសាលា និងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជូន **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា ដោយសារមានការស្នើសុំពីអន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ឱ្យក្រសួងពាណិជ្ជកម្មរៀបចំសិក្ខាសាលាខាងលើ ដើម្បីជួយឱ្យអង្គភាពរបស់ខ្លួនយល់ពីរបៀបសរសេរគម្រោងឱ្យត្រូវទៅនឹងគោលបំណងរបស់ **TDSP** ឈានទៅអនុវត្តផែនទីវិថីរបស់ Trade SWAp ដំណើរការទៅដូចដែលបានកំណត់ទុក។ សិក្ខាសាលានេះ នឹងប្រព្រឹត្តទៅនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១០ វេលាម៉ោង ០៨:៣០ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ឡូដ៍លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្មលេខ ១១៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ។

គោលបំណងនៃការរៀបចំកិច្ចប្រជុំនេះ គឺដើម្បីណែនាំអំពីរបៀបរៀបចំសរសេរឱ្យស្របតាមយុទ្ធសាស្ត្រកម្មវិធីរបស់ Trade SWAp ផែនទីវិថីទី១ ទី២ និងទី៣ ហើយជាពិសេសទៅទៀតនោះត្រូវឱ្យធានា និងសមស្របតាមទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៣។ លើសពីនេះទៅទៀត ការរៀបចំឱ្យសំណើបានល្អ និងធ្វើឱ្យចំណេញពេលវេលានៃការអនុវត្តគម្រោង។ សិក្ខាសាលានេះរៀបចំឡើងក្រោមអធិបតីភាព ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម។

អាស្រ័យដូចបានជំរាបជូនខាងលើសូម **ឯកឧត្តម លោកជំទាវ** មេត្តាចាត់បញ្ជូនសមាជិកនៃគណៈកម្មាធិការដូចបានជំរាបជូនខាងលើចូលរួមក្នុងសិក្ខាសាលានេះ ដោយបញ្ជូនឈ្មោះមកនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងពាណិជ្ជកម្មឱ្យបានមុន **ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១០** ដើម្បីឱ្យក្រសួងរៀបចំ Logistics បានល្អប្រសើរ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**ប៉ាន_សូរស័ក្តិ**

***ចម្លងជូន :***

-ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី

-ឯកសារ-កាលប្បវត្តិ

***ទំនាក់ទំនងចូលរួមនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ :***

ទូរស័ព្ទ : ០២៣ ៨៦៦ ០៦៤

: ០១៧ ៩៧៧ ៦៩៦

: ០១៦ ២០៣ ៣៣៣

អ៊ីមែល : seng.ramy@gmail.com

long.kemvichet@gmail.com